ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រៃវែង

សាលក្រមលេខ: ២៦/០៧ (ខ)
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ: ២២៤
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ:១៤២មខ
ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ:៤១០
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រៃវែង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៣ ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តព្រៃវែង

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ២២៤ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] យ៉ាំងញៀង ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិ វៀតណាម មុខរបរ នេសាទត្រី ទីកន្លែងកំណើតនៅ ភូ[redacted] ខេត្តព្រៃវែង និងមានទីលំនៅបច្ចុប្បន្ន[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] យ៉ាំងធុង "រស់" ម្ដាយឈ្មោះ [redacted] ធីហៀង "រស់" ប្រពន្ធឈ្មោះ [redacted] ធីងាំ "រស់" មានកូនចំនួន ០៦នាក់ ជានីតិជន ។ (ក្រៅឃុំ )(អវត្តមាន)

ប្រវត្តិនៃការផ្តន្ទាទោសតុលាការពីមុន គ្មាន ។

ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] (អវត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted]ធីរៀង ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិ វៀតណាម រស់នៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ។(វត្តមាន)

-ជនរងគ្រោះ ឈ្មោះ [redacted] យ៉ាំងចាយ ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិ វៀតណាម រស់នៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ។(វត្តមាន)

-សាក្សី ឈ្មោះ [redacted] ធីវ៉ៅ ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិ វៀតណាម រស់នៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ។(វត្តមាន)

-**បានឃើញ** របាយការណ៍សរុបករណី ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពាមរក៍ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ១១៨ អក(ខ)/០២២ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រៃវែង ។

-**បានឃើញ** ដីកាដំណោះស្រាយស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះលេខ: ២៩៥៤ ជស.ព្រ៩/២០២២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែលប្រាំបី និងសាមសិបនាទីយប់ ជនរងគ្រោះឈ្មោះ [redacted] យ៉ាំងចាយ ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិវៀតណាម មានទីលំនៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង បានផឹកស្រាស្រវឹង ហើយស្រែកជេរប្រមាថទៅលើជនសង្ស័យឈ្មោះ [redacted] យ៉ាំងញៀង ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិវៀតណាម មានទីលំនៅភូមិឃុំជាមួយគ្នាថា អាចុយម្រាយអាញៀង អញចាក់ម្ហែងចុយម្រាយឥឡូវហើយ ហើយឈ្មោះ [redacted] យ៉ាំងញៀង បានតបទៅវិញថា អាអូនម្ហែងកុំខ្លាំងពេក រួចហើយឈ្មោះ [redacted] យ៉ាំងញៀង បានទៅយកកូនកាំបិតចុងស្រួចនៅលើហ៊ឹងកុងម៉ា កាន់ដើរចេញទៅក្រៅផ្ទះ ពេលនោះឈ្មោះ [redacted] យ៉ាំងចាយ ឃើញ ក៏រត់មករកវាយឈ្មោះ [redacted] យ៉ាំងញៀង តែក៏ត្រូវឈ្មោះ [redacted] យ៉ាំងញៀង ចាក់មួយកាំបិតត្រូវចំត្រង់ក្រោមដោះខាងស្តាំ បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ហើយត្រូវបានក្រុមគ្រួសារបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ចំណែកឈ្មោះ [redacted] យ៉ាំងញៀង ក៏ត្រូវបានកូនរបស់ជនរងគ្រោះរាយការណ៍ប្តឹងសមត្ថកិច្ចឱ្យធ្វើការចាប់ឃាត់ខ្លួនតែម្តង ។

## នាពេលសវនាការ

-តាមកំណត់ហេតុចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងញៀង បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃកើតហេតុ ឈ្មោះ [redacted] យ៉ាំងចាយ បានមកអង្គុយផឹកស្រានៅលើគ្រែមុខផ្ទះខ្លួន ហើយបានស្រែកជេរខ្លួនថា អាចុយម្រាយ អាញៀង អញចាក់ហ្អែងចុយម្រាយឥឡូវហើយ ពេលនោះខ្លួនកំពុងនៅក្នុងផ្ទះក៏បានតបទៅវិញថា អាអូនម្ហែងកុំខ្លាំងពេក។ ពេលនិយាយរួច ខ្លួនបានដើរទៅយកកាំបិតចុងស្រួចនៅលើហ៊ឹងកុងម៉ា កាន់ដើរចេញមកក្រៅផ្ទះ ពេលខ្លួនដើរពីផ្ទះបានប្រហែលជា ៥ម៉ែត្រ ក៏ឃើញឈ្មោះ [redacted] យ៉ាំងចាយ រត់ចេញពីផ្ទះវា រត់សំដៅមករកខ្លួន ដោយរត់មកបុកកាំបិតដែលខ្លួនបានកាន់ពីមុខ បណ្តាលឱ្យមុតដួលនឹងកន្លែង ហើយពួកខ្លួនមិនដែលមានជម្លោះជាមួយគ្នាពីមុនមកនោះទេ ចំណែកកាំបិតនោះគឺខ្លួនរើសបានប្រហែល ១០ថ្ងៃមុនកើតហេតុ ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីវៀង ឆ្លើយនាពេលសវនាការថា ខ្លួនមិនបានឃើញហេតុការណ៍ផ្ទាល់ទេ គឺដឹងដោយសារបងស្រីខ្លួនឈ្មោះ ហៀង តេទូរស័ព្ទមកប្រាប់ ពេលទៅដល់កន្លែងកើតហេតុខ្លួនបានឃើញឪពុកកំពុងដេក ហើយដៃម្ខាងខ្ទប់មុខរបួស បាត់ទៅហើយ ។ បន្ទាប់មកក៏បានបងខ្លួន និងអ្នកជិតខាងដាក់ឡានបញ្ជូនទៅមន្ទីរពេទ្យ តែម្តង ។ ចំពោះសំណងថ្លៃព្យាបាល និងសំណងជម្ងឺចិត្ត គឺខ្លួនមិនទាមទារអ្វីបន្ថែមទេ ព្រោះគ្រួសាររបស់ឈ្មោះ [redacted] យ៉ាំងញៀង បានឲ្យថ្លៃព្យាបាលឪពុកខ្លួនរួចហើយ ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] យ៉ាំងចាយ ឆ្លើយនាពេលសវនាការថា កាលពីថ្ងៃកើតហេតុខ្លួនបានផឹកស្រាថ្នាំជាមួយឈ្មោះ ខាង ផឹកអស់កន្លះលីត្រ ខ្លួនឈប់ផឹក ក៏ត្រឡប់មកផ្ទះវិញ។ លុះម៉ោងប្រហែល៦ល្ងាច ខ្លួនបានដើរទៅទិញបារីនៅខាងលិចជាប់ផ្ទះឈ្មោះ [redacted] យ៉ាំងញៀង ។ ពេលដើរទៅដល់មុខផ្ទះអ្នកលក់ខ្លួនបានតេទូរស័ព្ទហៅប្អូនខ្លួនមកលេងផ្ទះខ្លួន ហើយប្អូនខ្លួនឆ្លើយថា មិនបានមកទេ ខ្លួនក៏បាននិយាយថា អ្វែងក្បត់អញអ្វែង ពេលនោះស្រាប់តែឈ្មោះ [redacted] យ៉ាំងញៀង ដើរចេញពីផ្ទះ មកដល់ចាក់ខ្លួនមួយកាំបិតមុតចំក្រោមដោះខាងស្តាំ បណ្តាលឲ្យខ្លួនដួលសន្លប់នៅមុខផ្ទះអ្នកលក់បារីតែម្តង ហើយខ្លួនមិនដែលមានទំនាស់ជាមួយគ្នានោះទេ ចំណែកថ្ងៃកើតហេតុខ្លួនក៏មិនបានជេរឈ្មោះ [redacted] យ៉ាំងញៀង ដែរ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ធីវី ឆ្លើយនាពេលសវនាការថា កាលពីថ្ងៃកើតហេតុខ្លួនបានលឺឈ្មោះ [redacted] យ៉ាំងញៀង រអ៊ូនៅផ្ទះគាត់ប្រហែលកន្លះម៉ោង ក៏លឺមាត់ឈ្មោះ [redacted] យ៉ាំងចាយ និយាយថា អ្វែងថាឲ្យអញស៊ីខ្សែលើស្តី បន្ទាប់មកក៏លឺបប្លលវាយគ្នា តែខ្លួនមិនដឹងថាអ្នកណាបប្លលអ្នកណាទេ ។ បានបន្តិចក៏លឺឈ្មោះ[redacted] យ៉ាំងចាយស្រែកថា អាញៀង ចាក់អញហើយវើយ ។ ពេលនោះខ្លួន និងម្តាយខ្លួនបានបើកទ្វារមើលតែខ្លួនមិនឃើញអ្វីទេ ព្រោះយប់ងងឹត បន្ទាប់មកម្តាយខ្លួនបានបញ្ចាំងពិលទៅមើលជិត ហើយស្រែកថាឈាមច្រើនណាស់ ខ្លួនក៏រត់ទៅមើលឃើញឈ្មោះ[redacted] យ៉ាំងចាយ ដេកយកដៃអោបពោះ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទដើមបណ្តឹង ជនរងគ្រោះ និងសាក្សីខាងលើរួចមក លោកស្រីសុំតម្កល់ការចោទប្រកាន់ដដែលដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរនៅដដែល ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីពិនិត្យសំណុំរឿង និងសួរដេញដោល ឃើញថា៖

១.ភស្តុតាងនៅក្នុងសំណុំរឿង ដែលដាក់បន្ទុកមកកូនក្តីខ្លួនមានតែចម្លើយរបស់ដើមបណ្តឹងដែលមិនដឹងរឿងអ្វីនៅពេលកើតហេតុ និងចម្លើយរបស់សាក្សីដែលមិនបានឃើញកូនក្តីរបស់ខ្លួនចាក់ទៅលើឈ្មោះ [redacted] យ៉ាំងចាយ ដោយផ្ទាល់ភ្នែកនោះទេ ។ ដូច្នេះមិនមានតម្រុយពិរុទ្ធភាពគ្រប់គ្រាន់ដែលអាចចោទប្រកាន់មកលើកូនក្តីខ្លួនបាននោះទេបើយោងតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

២.ផ្អែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលបានឆ្លើយគឺមានវិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣.បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទដែលជាកូនក្តីខ្លួន និងកាលៈទេសៈនៃការប្រព្រឹត្តនោះគឺ កូនក្តីខ្លួនមានវ័យចាស់ជរាហើយជនរងគ្រោះជាអ្នករត់ទៅវាយកូនក្តីខ្លួនហើយដួលត្រូវចំកាំបិតដែលកូនក្តីខ្លួនកាន់បណ្តាលឱ្យរបួស មិនមែនកូនក្តីខ្លួនយកកាំបិតចាក់ជនរងគ្រោះទេ ។

៤.បើផ្អែកតាមចម្លើយរបស់កូនក្តីខ្លួនទៅដំណាក់កាលស៊ើបសួរ ក៏ដូចជាការសួរដេញដោលរួចមក គឺកូនក្តីខ្លួនគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសទេ គឺជនរងគ្រោះជាអ្នករត់បុកកាំបិតខ្លួនឯង ។

៥.កូនក្តីខ្លួន និងដើមបណ្តឹងបានសម្របសម្រួលគ្នារួចរាល់ហើយ ម្យ៉ាងទៀតកូនក្តីខ្លួនមិនបានរត់គេចវេសទៅណាទេ ព្រោះកូនក្តីខ្លួនជាជនស្លូតត្រង់មិនដែលប្រព្រឹត្តអំពើណាមួយដែលបង្កចលាចលដល់សង្គមនោះទេ ម្យ៉ាងក្រោយកើតហេតុកូនក្តីរបស់ខ្លួនយល់ព្រមសហការជាមួយអាជ្ញាធរ និងតុលាការទៀតផង។

ហេតុនេះ សុំឱ្យតុលាការលើកលែងចោទប្រកាន់កូនក្តីរបស់ខ្លួនពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ផង ពីព្រោះកូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

.ក្រោយពីបានស្តាប់កំណត់ហេតុចម្លើយរបស់ជនជាប់ចោទ

.ក្រោយពីស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

.ក្រោយពីស្តាប់ចម្លើយរបស់ជនរងគ្រោះ

.ក្រោយពីស្តាប់ចម្លើយរបស់សាក្សី

.ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

.ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

.ក្រោយពីបានពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង

.ក្រោយពីបានពិនិត្យពិចារណានិងពិភាក្សាត្រឹមត្រូវតាមច្បាប់រួចហើយ

## សាលាដំបូងខេត្តព្រៃវែង

## យល់ឃើញថា

## ៣.ផ្នែកសំអាងហេតុ

១.កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ ពិតជាមានបទល្មើស **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងញៀង ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិ វៀតណាម បានយកកាំបិតចាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] យ៉ាំងចាយ ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិ វៀតណាម ត្រូវចំក្រោមដោះខាងស្តាំ បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ ពិតប្រាកដមែន ។



Scanned with CamScanner

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងញៀង បានឆ្លើយនៅដំណាក់កាលស៊ើបសួរថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការ ដោយកាលពីថ្ងៃកើតហេតុវេលាម៉ោងប្រហែល ប្រាំបី និងសាមសិបនាទីយប់ ឈ្មោះ [redacted] យ៉ាំងចាយ ដែលរស់នៅភូមិឃុំជាមួយខ្លួន (ផ្ទះទល់មុខផ្ទះខ្លួនរាងបញ្ឆិតគ្នាបន្តិច) បានអង្គុយផឹកស្រាស្រវឹងនៅលើគ្រែមុខផ្ទះរបស់វា ហើយស្រែកជេរមកលើខ្លួនថា អាចុយម្រាយ អាញៀង អញចាក់ហ្វែងចុយម្រាយឥឡូវហើយ ពេលនោះខ្លួនកំពុងនៅក្នុងផ្ទះក៏បានតបទៅវិញថា អាអូនអ្វែងកុំខ្លាំងពេក ។ពេលនិយាយរួច ខ្លួនបានដើរទៅយកកាំបិតចុងស្រួចនៅលើហ៊ីងកុងម៉ា កាន់ដើរចេញមកក្រៅផ្ទះ ពេលខ្លួនដើរពីផ្ទះបានប្រហែលជា ៥ម៉ែត្រ ក៏ឃើញឈ្មោះ [redacted] យ៉ាំងចាយ រត់ចេញពីផ្ទះវា រត់សំដៅមករកខ្លួន ដោយរត់មកបុកកាំបិតដែលខ្លួនបានកាន់ពីមុខ បណ្ដាលឱ្យមុតដួលនឹងកន្លែង ប៉ុន្តែខ្លួនមិនដឹងថាមុតត្រង់ណានោះទេ ។ ចំពោះចម្លើយរបស់ជន ជាប់ចោទដែលបានឆ្លើយថា ជនរងគ្រោះបានរត់សំដៅមកខ្លួន និងរត់មកបុកកាំបិតដែលខ្លួនបានកាន់ដាក់ពីមុខនោះមិនមានភស្តុតាងអ្វីយកមកបញ្ជាក់នោះទេ ដោយហេតុថា តាមចម្លើយរបស់ជនរងគ្រោះបានឆ្លើយថា ជនជាប់ចោទបានដើរចេញមកពីផ្ទះមកដល់បានយកកាំបិតចាក់ចំក្រោមដោះខាងស្ដាំ ហើយតាមចម្លើយសាក្សី ឈ្មោះ [redacted]ង ធីវ៉េ ក៏បានឆ្លើយថា លឺមាត់ជនជាប់ចោទ និងជនរងគ្រោះបប្លូលវាយគ្នាបានតែបន្តិចក៏លឺ ជនរងគ្រោះស្រែកថាជនជាប់ចោទចាក់ជនរងគ្រោះហើយ ដូចនេះ យោងតាមសំអាងនេះ បូករួមទាំងរបាយការណ៍សរុបករណី របស់អធិការដ្ឋាននគរបាលស្រុកពាមរក៍ នៃស្នងការ ដ្ឋាននគរបាលខេត្តព្រៃវែង អាចឱ្យតុលាការជឿបានថាជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៣.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]យ៉ាំងញៀង ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ទៅលើជនរងគ្រោះឈ្មោះ [redacted] យ៉ាំងចាយ ពិតប្រាកដមែន ដោយនៅថ្ងៃកើតហេតុជនជាប់ចោទបានឈ្លោះជាមួយជនរងគ្រោះ រួចបានយកកាំបិតចុងស្រួចចាក់ចំត្រង់ក្រោមដោះខាងស្ដាំមួយកាំបិតបណ្ដាលឱ្យជនរងគ្រោះរងរបួស ។ ដូចនេះអំពើរបសជនជាប់ចោទនេះបានរំលោភលើមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៤.ដើមបណ្ដឹងឈ្មោះ [redacted] ធីវៀង បានបញ្ជាក់ថាគ្រួសាររបស់ជនជាប់ចោទ បានជួសជុលសំណង់ថ្លៃថ្នាំនិងថ្លៃព្យាបាលឱ្យឪពុកដែលជាជនរងគ្រោះរួចរាល់អស់ហើយ ដូច្នេះមិនទាមទារសំណងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្តអ្វីបន្ថែមទៀតទេ ។ ដូច្នេះ គប្បីតុលាការគួរពិចារណាតាមច្បាប់ ។

៥.តំណាងអយ្យការបានសន្និដ្ឋានប្ដឹងសុំថា ក្រោយពីបានស្ដាប់ការសួរដេញដោលក្នុងអង្គសវនាការឃើញថា ចម្លើយរបស់ជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹង និងសាក្សី មានលក្ខណៈស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] យ៉ាំងញៀង ពិតជាបានប្រកាន់ដូចការចោទប្រកាន់ ។ ដូច្នេះតំណាងអយ្យការសុំតម្កល់បទចោទប្រកាន់ដដែល និងស្នើសុំតុលាការផ្ដន្ទាទោសជនជាប់ចោទ ហេតុនេះ គប្បីតុលាការពិចារណាតាមច្បាប់។

៦.សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted]យ៉ាំងញៀង បាននិយាយសំដីចុងក្រោយថា ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទ ដូច្នេះគប្បីតុលាការពិចារណាតាមជាក់ស្ដែង ។

៧.វត្ថុចាប់យក កាំបិតស្តើងមុខពណ៌សបាក់ផ្តែកាំបិតមួយកំណាត់ ប្រវែង ១២សង់ទីម៉ែត្រ ទទឹងប្រវែង ១ សង់ទីម៉ែត្រ ចំនួន ០១ គប្បីសម្រេចរឹបអូសបំផ្លាញចោល ។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]យ៉ាំងញៀង ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិ វៀតណាម ពីបទ **ហិង្សាដោយចេតនាមានស្ថាន**ទម្ងន់ទោស ប្រព្រឹត្តនៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិ ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៩ អំពើរបស់ជនជាប់ចោទគឺ កើតចេញពីការឈ្លោះប្រកែកគ្នា ហើយជនរងគ្រោះបានរត់ទៅចូលសំដៅទៅរកជនជាប់ចោទ រួចពេលនោះជនជាប់ចោទមានកូនកាំបិតនៅនឹងដៃក៏បានជ្រុលចាក់ចំមួយកាំបិតទៅលើជនរងគ្រោះ ហើយមកទល់បច្ចុប្បន្ននេះជនជាប់ចោទបានជួសជុលសំណងការខូចខាត និងជំងឺចិត្តឲ្យជនរងគ្រោះរួចរាល់ហើយដែរ ដែលគប្បី តុលាការយកមកពិចារណាក្នុងការផ្តន្ទាទោស ។

<u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] យ៉ាំងញៀង ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិ វៀតណាម ដាក់ពន្ធនាគារកំណត់រយៈពេល០៣ (បី) ឆ្នាំ ដោយអោយអនុវត្តទោសក្នុងពន្ធនាគាររយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ទោសដែលនៅសល់អនុវត្តទោសព្យួរធម្មតា ពីបទ ហិង្សា**ដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិ ២១៨ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

**២**.រឹបអូសវត្ថុចាប់យក កាំបិតស្តើងមុខពណ៌សបាក់ផ្តែកាំបិតមួយកំណាត់ ប្រវែង ១២សង់ទីម៉ែត្រ ទទឹងប្រវែង ១សង់ទីម៉ែត្រ ចំនួន ០១ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹង និងកំបាំងមុខជនជាប់ចោទ ។

-ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner